**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

លេខ..៣០៨១./១៧ សន ៣

កំពង់ធំ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៧

**ជម្រាបមក**

**- លោកអភិបាល ក្រុងស្ទឹងសែន**

**- លោកអភិបាល ស្រុកស្ទោង**

**កម្មវត្ថុ:** ស្តីពីការវាយតម្លៃកិច្ចសន្យាបំពេញការងាររបស់បុគ្គលិកគាំទ្របច្ចេកទេសក្រុង-ស្រុកក្រោយការសាកល្បងការងារដែលមានរយៈពេល ៣ ខែ( ឧសភា-កក្កដា ) ។

**យោង:** -លិខិតលេខ ៤៤៤ សជណ / គ ជ អ ប ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការវាយតម្លៃការបំពេញការងារប្រចាំឆ្នាំរបស់បុគ្គលិកដែលពាក់ព័ន្ធ និងការអនុវត្តន៍កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតយ្យនៅថ្នាក់ក្រោមជាតិ

-អ៊ីម៉ែលរបស់លេខាធិការដ្ឋាន គ ជ អ ប ស្តីពីការវាយតម្លៃបញ្ចប់កិច្ចសន្យារយៈពេលការសាកល្បងការងារ ០៣ ខែ របស់បុគ្គលិកគាំទ្របច្ចេកទេសក្រុង-ស្រុក

តបតាមកម្មវត្ថុ និងយោងខាងលើសូមជម្រាបជូនលោកអភិបាល នៃគណៈអភិបាល ក្រុងស្ទឹងសែន ស្រុកស្ទោង ជ្រាបថា៖ ផ្អែកតាមការណែនាំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ ជ អ ប )លក្ខខ័ណ្ឌកិច្ចសន្យាការវាយតម្លៃប្រចាំឆ្នាំនិងការសាកល្បងការងាររយៈពេល ៣ ខែ លើការបំពេញការងាររបស់បុគ្គលិកដែលពាក់ព័ន្ធ និងការអនុវត្តន៍កម្មវិធីជាតិ (IP3) មានសារៈសំខាន់ដើម្បីត្រួតពិនិត្យឡើងវិញលើការបំពេញការកិច្ចរបស់បុគ្គលិកដោយធ្វើការប្រៀបធៀបជាមួយលក្ខខ័ណ្ឌការងារបុគ្គលិកម្នាក់ៗ។

ក្នុងន័យនេះ សាលាក្រុងស្ទឹងសែន និងសាលាស្រុកស្ទោង ត្រូវរៀបចំដំណើរការវាយតម្លៃកិច្ចសន្យាការងារ លោក **អេង ដារិទ្ធី** និងលោកស្រី ណើ ចំរើន ជាបុគ្គលិកគាំទ្របច្ចេកទេស ក្រុងស្ទឹងសែន និងស្រុកស្ទោង ក្រោយពីការសាកល្បងការងាររយៈពេល ៣ ខែ កន្លងមក គឺចាប់ពីថ្ងៃទី០២ ខែ ឧសភា ដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៧។ រួចហើយស្រុកត្រូវរៀបចំរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការវាយតម្លៃផ្ញើជូនមកមន្ត្រីបច្ចេកទេសគ្រប់គ្រងបុគ្គលិកអោយបានត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៧ ដើម្បីពិនិត្យនិងរៀបចំផ្ញើជូន( គ ជ អ ប )ពិនិត្យ និងសម្រេច ។

អាស្រ័យហេតុនេះសូមលោកអភិបាលក្រុងស្រុកចាត់ចែងអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូម លោក អភិបាលក្រុង-ស្រុក ទទួលនូវការរាប់អានពីខ្ញុំ ។

**អភិបាល**

សុខ~លុ